# សេចក្តីណែនាំស្តីពីការបោះឆ្នោតបាន ឬកាបោះឆ្នោតពុំបាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គ.ជ.ប

## សេចក្តីណែនាំ

### ស្តីពីការបោះឆ្នោតបាន ឬការបោះឆ្នោតពុំបាន

**បន្ទាប់ពីបានពិនិត្យដោយផ្ទៀងផ្ទាត់រវាងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ**
**ឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត រូបថត និងរូបពិតរបស់អ្នកបោះឆ្នោត**

**អនុញ្ញាតឱ្យបោះឆ្នោតបាន ៖**

១. បើឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត រូបថត និងរូបពិតរបស់អ្នកបោះឆ្នោតដូចគ្នា

២. បើឈ្មោះ ថ្ងៃខែឆ្នាំកំណើត រូបថត និងរូបពិតដូចគ្នា ប៉ុន្តែ ខុសភេទ

៣. បើរូបពិត ចាស់ជាង ឬក្មេងជាងអាយុក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ប៉ុន្តែឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ដូចគ្នានឹងឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើតក្នុងបញ្ជីបោះឆ្នោត ។

**បន្តពិនិត្យថាអាចឱ្យបោះឆ្នោតបាន ឬពុំបាន ៖**

១. បើរូបថត និងរូបពិតដូចគ្នា តែឈ្មោះសរសេរខុសអក្ខរាវិរុទ្ធ ដូចជា ខ្វះ ឬលើស ស្រៈ ព្យញ្ជនៈ ជើងអក្សរ វណ្ណយុត្ត តែឱ្យមានសូរសំឡេងដូចគ្នានោះត្រូវបន្តពិនិត្យ ៖

* **ឱ្យបោះឆ្នោតបាន** បើភេទ ថ្ងៃខែឆ្នាំកំណើតដូចគ្នា
* **ពុំអនុញ្ញាតឱ្យបោះឆ្នោត** បើភេទ ឬ ថ្ងៃខែឆ្នាំកំណើតខុសគ្នា ។

២. **បន្តពិនិត្យទិន្នន័យផ្សេងទៀត** ដើម្បីឱ្យប្រាកដថាឈ្មោះណាមួយដែលត្រូវអនុញ្ញាតឱ្យបោះឆ្នោតក្នុងករណីឈ្មោះពីរ ឬច្រើនដូចគ្នា ឬស្រដៀងគ្នា ។

**អញ្ជើញទៅជួបប្រធានការិយាល័យបោះឆ្នោត ៖**

* បើលេខាធិការរកមិនឃើញឈ្មោះលោកអ្នកក្នុងបញ្ជីបោះឆ្នោត
* បើលេខាធិការពុំទទួលស្គាល់ឈ្មោះលោកអ្នកក្នុងបញ្ជីបោះឆ្នោត ឬក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់លោកអ្នក ។

**សូមលើកការជំទាស់ទៅប្រធានការិយាល័យបោះឆ្នោត ៖**

* បើឃើញលេខាធិការអនុញ្ញាតឱ្យបោះឆ្នោតដោយប្រើ "**ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត**"
* បើឃើញលេខាធិការអនុញ្ញាតឱ្យបោះឆ្នោតដោយប្រើ "**ឯកសារណាមួយដែលច្បាប់ពុំអនុញ្ញាត**" ។